ការចេញផ្សាយលើកទី៤ ខែធ្នូ ឆ្នាំ ២០១៩

មាតិកា

១. កិច្ចសន្ទនាបុរស និងយេនឌ័រកាហ្វេ ៖ បង្កើនការយល់ដឹង និងទំនុកចិត្ត
២. លោកស្រី អេង ម៉ាណារី, ជនបង្គោលយេនឌ័រ “ខ្ញុំមានកិត្តិយសក្នុងការលើកកម្ពស់សមភាពយេនឌ័រ”
៣. លទ្ធផលនៃការសិក្សាទិន្នន័យដើមអាចទាញយកបាននៅលើអ៊ីនធឺណិតដោយឥតគិតថ្លៃ
៤. ការអរគុណទៅដល់ម្ចាស់ជំនួយរបស់ពួកយើង
៥. ទំនាក់ទំនង

# TIGER

លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន

TEACHING FOR IMPROVED GENDER EQUALITY AND RESPONSIVENESS

## កិច្ចសន្ទនាបុរស និងយេនឌ័រកាហ្វេ ៖ បង្កើនការយល់ដឹង និងទំនុកចិត្ត

នៅក្នុងគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន យើងបានប្រជុំជាមួយថ្នាក់ដឹកនាំសាលា និងគ្រូដើម្បីពិភាក្សាអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុង និងជុំវិញសាលារៀន។

បុរសត្រូវបានជំរុញឲ្យចូលរួមនៅក្នុង**កិច្ចសន្ទនាបុរស**ដើម្បីឆ្លុះបញ្ចាំងពីភាពជាបុរសរបស់ខ្លួន និង ឥរិយាបថ ឬអាកប្បកិរិយារបស់បុរសដែលអាចចូលរួមចំណែកដល់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការយល់ដឹងរបស់ពួកគេនឹងរីកចម្រើនទាក់ទងនឹងតួនាទីដ៏មានឥទ្ធិពលរបស់ពួកគេនៅក្នុងសង្គម និងរបៀបដែលពួកគេអាចប្រើអំណាចនេះដើម្បីផ្លាស់ប្តូរស្ថានភាពមិនស្មើគ្នានាពេលបច្ចុប្បន្ន។

ផ្ទុយទៅវិញ **យេនឌ័រកាហ្វេ**ផ្តល់កន្លែងមួយដែលមានសុវត្ថិភាព មិនមានការវិនិច្ឆ័យសម្រាប់ស្ត្រីក្នុងការបង្ហាញពីបទពិសោធន៍របស់ពួកគេពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ គោលបំណងគឺដើម្បីកសាងទំនុកចិត្តរបស់ពួកគេក្នុងការអនុវត្តសិទ្ធិមនុស្សរបស់ពួកគេ។

ក្នុងករណីទាំងពីរនេះ ការប្រជុំត្រូវបានដឹកនាំដោយអ្នកចូលរួមដោយខ្លួនឯង ព្រោះពួកគេជាអ្នកជំនាញក្នុងបរិបទជាក់លាក់ និងជាមួយបទពិសោធន៍ជាក់លាក់របស់ពួកគេនោះ ដោយមានការចូលរួមជាធាតុចូល តិចតួចប៉ុណ្ណោះពីអ្នកសម្របសម្រួល។ សកម្មភាពនេះបង្កើតបានជាសហគមន៍ និងការទុកចិត្តគ្នារវាងសហការី ដើម្បីជួយគ្នាទៅវិញទៅមកដោះស្រាយស្ថានភាពលំបាក ឬដំណើរការនៃការគិតដែលមានបញ្ហា។

កិច្ចសន្ទនាបុរស និងយេនឌ័រកាហ្វេគឺជាផ្នែកសំខាន់មួយនៃគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន។ មុនពេលថ្នាក់ដឹកនាំសាលា និងគ្រូបង្រៀនអាចឈានទៅរកសក្តានុពលរបស់ពួកគេ និងក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរដែល**ប្រឆាំងនឹងផ្នត់គំនិតយេនឌ័រដោយជោគជ័យ** ពួកគេចាំបាច់ត្រូវយល់ដឹង និងដោះស្រាយភាពលំអៀងយេនឌ័រ និងជំនឿរបស់ពួកគេជាមុនសិន។ បន្ទាប់មកពួកគេអាចផ្លាស់ប្តូររបៀបដែលពួកគេអនុវត្តសកម្មភាពទាំងនេះទៅក្នុងថ្នាក់រៀន និងសាលារៀនរបស់ពួកគេបាន។

**ការឆ្លុះបញ្ចាំងមើលខ្លួនឯង និងការសន្ទនាបែបស្ថាបនា**ជាមួយដៃគូគឺជាគន្លឹះក្នុងការផ្លាស់ប្តូរវប្បធម៌ និងប្រពៃណីដែលមានអាយុកាលចំណាស់។ ប្រសិនបើគ្មានការការចូលរួមទូលំទូលាយទេ នោះវឌ្ឍនភាពប្រកបដោយចីរភាពមិនអាចកើតឡើងបានទេ។







## លោកស្រី អេង ម៉ាណាវី, ជនបង្គោលយេនឌ័រ៖ “ខ្ញុំមានកិត្តិយសក្នុងការលើកកម្ពស់សមភាពយេនឌ័រ”

“ខ្ញុំជាបុគ្គលិកផ្នែករដ្ឋបាលដែលកំពុងធ្វើការនៅសាលាបឋមសិក្សាអនុវត្តន៍ក្នុងក្រុងបាត់ដំបង។ កាលពីមុនខ្ញុំមានចំណេះដឹងតិចតួចអំពីទស្សនៈនៃតួនាទីយេនឌ័រ និងផ្នត់គំនិតយេនឌ័រ។ ខ្ញុំមិនហ៊ាននិយាយពីវាជាសាធារណៈទេ។ ខ្ញុំមានភាពខ្មាស់អៀន ហើយខ្ញុំតែងខ្វះនូវទំនុកចិត្តក្នុងការពិភាក្សាអំពីប្រធានបទដែលដែលអាចញាំងឱ្យមានការជជែកវែកញែក។ ខ្ញុំមានមោទនភាពក្នុងការនិយាយថា រឿងនេះ បានផ្លាស់ប្តូរហើយ។ ជាទូទៅ ខ្ញុំពិតជាមានកិត្តិយសណាស់ក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គម និងជាពិសេសនៅក្នុងដំណើរការបង្រៀន និងរៀន។

បន្ទាប់ពីបានចូលរួមនៅក្នុងយេនឌ័រកាហ្វេមក ខ្ញុំត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងវគ្គបំប៉នគម្រោង TIGER ស្តីពី ការសម្របសម្រួលវគ្គកិច្ចសន្ទនាបុរស និងយេនឌ័រកាហ្វេ។ ក្នុងអំឡុងវគ្គបំប៉ននេះខ្ញុំបានបង្កើនចំណេះដឹងរបស់ខ្ញុំទាក់ទងនឹងយេនឌ័រ ហើយខ្ញុំចាប់ផ្តើមមានអារម្មណ៍ជឿជាក់ក្នុងការសម្របសម្រួលការសន្ទនាជាក្រុម។



ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៩ ខ្ញុំបានជួយសម្របសម្រួលការរៀបចំយេនឌ័រកាហ្វេនៅក្នុងសាលារបស់ខ្ញុំ ហើយខ្ញុំបានជួយសហការីរបស់ខ្ញុំនៅក្នុងសាលារៀនជិតខាងចំនួន៣ថែមទៀត ។ ត្រង់ចំណុចនេះ ខ្ញុំមានទំនុកចិត្តក្នុងការជួយសម្របសម្រួលការរៀបចំយេនឌ័រកាហ្វេនេះ។ ខ្ញុំហ៊ាននិយាយ និងពិភាក្សាអំពីផ្នត់គំនិត និងបទដ្ឋានយេនឌ័រ ។ ខ្ញុំសប្បាយរីករាយដែលខ្ញុំអាចគាំទ្រដល់សហគមន៍របស់យើងក្នុងការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

លោកស្រី អេង ម៉ាណាវី

## លទ្ធផលនៃការសិក្សាទិន្នន័យដើមអាចទាញអាចយកបាននៅលើអ៊ីនធឺណិតដោយឥតគិតថ្លៃ

ក្រុមអ្នកស្រាវជ្រាវដែលមកពីសាកលវិទ្យាល័យ យេ យូវ ឡឺវេន (ប្រទេសបែលហ្ស៊ិក) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ប្រទេសកម្ពុជា) និងអង្គការ វី វី អូ ប៊ីនៅកម្ពុជាបានធ្វើការសិក្សាទិន្នន័យដើមអំពីហេតុការណ៍នៃអំពើហិង្សានៅក្នុងសាលារៀនទាក់ទងនឹងយេនឌ័រ (SRGBV) នៅប្រទេសកម្ពុជាដើម្បីវាយតម្លៃពីផលជះនៃការអនុវត្តគម្រោង TIGER របស់យើងនៅដំណាក់កាលក្រោយទៀត។ ការសិក្សាទិន្នន័យដើមបង្ហាញពីស្ថានភាពផ្សេងៗនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសាលារៀន។ ផលជះនៃការអនុវត្តគម្រោងនេះនឹងត្រូវធ្វើការវាស់វែងឆ្លើយតបនឹងស្ថានភាពនោះនៅដំណាក់កាលក្រោយទៀត។

យើងឃើញថាអត្រានៃការកើតមានជារូមនៃទម្រង់ផ្សេងៗគ្នានៃអំពើហិង្សាប្រឆាំងនឹងកុមារ និងរវាងកុមារនៅក្នុងបរិបទសាលារៀននៅប្រទេសកម្ពុជាមានកម្រិតខ្ពស់សំរាប់ភេទទាំងពីរ។ នាយកសាលា និងគ្រូមិនទាន់បានត្រៀមខ្លួនរួចរាល់ដើម្បីឆ្លើយតបនឹងអំពើហិង្សានៅក្នុងសាលារៀនទាក់ទងនឹងយេនឌ័រនៅឡើយទេ។ នេះគឺជាលទ្ធផលនៃកង្វះបទបញ្ជាផ្ទៃក្នុងលើបញ្ហានេះនៅក្នុងសាលារៀន។ ហេតុដូច្នេះហើយ គ្រូបង្រៀននៅតែបន្តប្រើការដាក់ទណ្ឌកម្មលើរាងកាយក្នុងការអនុវត្តវិធានការវិន័យ។ ការរកឃើញរបស់យើងអំពាវនាវឱ្យមានវិធីសាស្ត្រផ្អែកលើសហគមន៍ និងសម្រាប់សាលារៀនទាំងមូលដើម្បីលុបបំបាត់អំពើហិង្សានៅក្នុងសាលារៀនទាក់ទងនឹងយេនឌ័រ និងផ្លាស់ប្តូរវប្បធម៌ និងជំនឿដែលគាំទ្រអំពើហិង្សាទាំងនោះ។ ធាតុផ្សំទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន។ លោកអ្នកអាចទាញយកអត្ថបទទាំងមូលតាមតំណភ្ជាប់ខាងក្រោមនេះ៖ https://cambodia.vvob.org/en/download/baselinestudy/SRGBV

## អរគុណចំពោះម្ចាស់ជំនួយ និងព័ត៌មានទំនាក់ទំនង

THIS PROJECT IS CO-FUNDED BY THE EUROPEAN UNION

Belgium
partner in development

Flanders
State of the Art

ផ្ទះលេខB-53, បុរីពានិជ្ជកម្មកាណាឌីយ៉ា, ភូមិកម្មករ,
សង្កាត់ស្វាយប៉ោ, ក្រុងបាត់ដំបង, ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ៖ www.cambodia.vvob.be/tiger
បណ្តាញសង្គម Facebook៖ @vvobcambodia, @kapeaction,
@gadccambodia និង @pkoorganization

*This newsletter was produced with the financial support of the European Union. Its contents are the sole responsibility of VVOB, KAPE, GADC and PKO and do not necessarily reflect the view of the European Union. The Belgian and Flemish governments cannot be held responsible for its content.*